# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងថ្នាក់ដឹកនាំ បានអញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋ ចំនួន ៤៩គ្រួសារ



នាព្រឹកថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងថ្នាក់ដឹកនាំ បានអញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋ ចំនួន ៤៩គ្រួសារ ដែលទើបទទួលបានសិទ្ធដីធ្លីស្របច្បាប់ពីរាជរដ្ឋាភិបាល តាមរយៈក្រសួងឧស្សាហកម្ម និងសិប្បកម្ម កាន់កាប់ដីធ្លីទំហំ ៥,៧៧១ ម៉ែត្រការ៉េ នៅលើទីតាំងបុរីកម្មករ នៃរោងចក្រតម្បាញសំពត់ ខេត្តបាត់ដំបង នាព្រឹកនេះ។

នៅក្នុងដំណើរអញ្ជើញសួរសុខទុក្ខនេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានពាំនាំនូវនៅសេចក្តីនឹករឭក និងការសួរសុខទុក្ខ ពីសំណាក់ សម្តេចតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ដែលតែងតែយកចិត្តទុកដាក់ ពីសុខទុក្ខរបស់ប្រជាពលរដ្ឋ និងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ មិនថាទីជិត ឬទីឆ្ងាយ។



ជាក់ស្តែង ចំពោះករណីប្រជាពលរដ្ឋទាំង ៤៩គ្រួសារ ភាគច្រើនជាអតីតគ្រួសារកម្មករ ដែលបាន រស់នៅលើដីបុរីកម្មករ នៃរោងចក្រតម្បាញសំពត់ ខេត្តបាត់ដំបង ជាទ្រព្យសម្បត្តិរដ្ឋ ក្នុងបញ្ជីសារពើភណ្ឌ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មត្រូវបាន **សម្តេចតេជោ** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងឧស្សាហកម្ម និងសិប្បកម្ម សម្រេចប្រគល់សិទ្ធស្របច្បាប់ ជូនពួកគាត់ទាំង ៤៩គ្រួសារ កាន់កាប់លើដីដែលពួកគាត់ កំពុងរស់នៅ និងប្រកបរបរចិញ្ចឹមជីវិត។



ថ្លែងក្នុងឱកាសនោះដែរ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានលើកឡើងថា ការមានកម្មសិទ្ធដីធ្លីស្របច្បាប់ ប្រជាពលរដ្ឋមានលំនឹងផ្លូវចិត្ត អាចប្រកបរបរចិញ្ចឹមជីវិត ដោយស្ងប់អារម្មណ៍ និងមានពេលវេលាគ្រប់គ្រាន់ គិតគូពីការរកទទួលទាន លែងមានការព្រួយបារម្មណ៍ ក្នុងចិត្តពីការបាត់បង់ទីជម្រក ហើយធ្វើអោយជីវភាពកាន់ប្រសើរ។

ជាការឆ្លើយតប ប្រជាពលរដ្ឋទាំង ៤៩ គ្រួសារ ដែលបានទទួលសិទ្ធកាន់កាប់ដីស្របច្បាប់ពីរាជរដ្ឋាភិបាល បានសម្តែងនូវសេចក្តីសប្បាយរីករាយ ជាពន់ពេក និងសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ តាមរយៈលោក ចម ប្រសិទ្ធ ជូនចំពោះ **សម្តេចតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលជានិច្ចកាលតែងគិតគូពីសុខទុក្ខ របស់ប្រជាពលរដ្ឋ។



